International Labour Organization

# ការបង្ការ និងកាត់បន្ថយការឆ្លងមេរោគកូវីត-១៩ នៅកន្លែងការងារ

## តារាងត្រួតពិនិត្យសកម្មភាព

កាលបរិច្ឆេទ៖ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០

តារាងត្រួតពិនិត្យនេះ គឺជាឧបករណ៍ជំនួយសម្រាប់ថ្នាក់គ្រប់គ្រង ក្នុងការអនុវត្តនូវសកម្មភាពកាត់បន្ថយ ការរីករាលដាលនៃជម៉្ងឺកូវីដ-១៩នៅកន្លែងការងារ។ ភាពជោគជ័យ នៃការអនុវត្តតាមឧបករណ៍ជំនួយនេះ គឺអាស្រ័យទៅនឹងកិច្ចសហការរវាងនិយោជក ប្រធានផ្នែក និងកម្មករនិយោជិត ដើម្បីធ្វើការកែប្រែជាវិជ្ជមាននៅក្នុងកន្លែងការងារ ក្នុងគោលដៅកែលម្អទៅលើការឆ្លើយតប និងរៀបចំត្រៀមអោយបានរួចរាល់និងត្រឹមត្រូវ ក្នុងការកាត់បន្ថយការរីករាលដាល នៃជម៉្ងឺកូវីដ-១៩។

និយោជក គួរតែចាត់ចែងអោយគណកម្មការសុខភាព និងសុវត្ថិភាពការងារ ឬ ក្រុមការងារសុវត្ថិភាព ចូលរួមក្នុងដំណើរការនៃការអនុវត្តនេះ។

### វិធីប្រើប្រាស់តារាងត្រួតពិនិត្យ៖

- 1. ចាត់តាំងក្រុមការងារ រួមមាន ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ប្រធានផ្នែក ឬក្រុម តំណាងកម្មករនិយោជិត និងបុគ្គលិកទទួលខុសត្រូវ ផ្នែកសុខភាព និងសុវត្ថិភាព នៅកន្លែងការងារ។
- 2. ផ្តល់ការបណ្តុះបណ្តាល ទៅឲ្យក្រុមការងារ អំពីជំហ៊ាននៃការអនុវត្តតារាងត្រួតពិនិត្យនេះ
- 3. បំពេញនូវតារាងត្រួតពិនិត្យ និងកត់ត្រាទុកនូវលទ្ធផលដែលបានអនុវត្ត
- 4. ក្រុមការងារត្រូវរៀបចំផែនការ ដោយមានកំនត់អ្វីដែលត្រូវធ្វើ ដោយនរណា នៅពេលណា និងស្វែងរកមធ្យោបាយក្នុងការអនុវត្តនូវវិធានការ ដែលបានកំណត់។ ប្រសិនចាំបាច់អាចស្វែងរកការផ្តល់មតិយោបល់ពី ប្រធានផ្នែកឬ កម្មករនិយោជិតទៅតាមផ្នែកនីមួយៗ
  - ប្រសិនបើវិធានការ ត្រូវបានអនុវត្តរួចរាល់ហើយ ឬមិនចាំបាច់សូមជ្រើសរើស "ទេ" ចំពោះសំនួរដែលសួរថា "តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?"
  - ប្រសិនបើអ្នកគិតថា ត្រូវការវិធានការសម្រាប់អនុវត្ត សូមជ្រើសរើស "បាទឬចា៎"
  - សូមកត់ត្រា ចូលនូវកំណត់សម្គាល់ផ្សេងៗ ដោយបរិយាយអំពីស្ថានភាពឬសំណូមពរផ្សេងៗ
- 5 . សូមមើលម្តងទៀត នូវចំនុច ដែលអ្នកបានឆ្លើយថា "បាទឬចា៎" ប្រសិនបើអ្នកគិតថា វាមានសារៈសំខាន់ ឬចាំបាច់ខ្លាំង អ្នកអាចគូសរង្វង់លើពាក្យ "អាទិភាព"។ [1]
- 6. បន្ទាប់ពីបញ្ចប់ការបំពេញតារាងត្រួតពិនិត្យ សូមធ្វើការពិភាក្សាជាមួយនឹងក្រុមការងារ ដើម្បីរៀបចំសំណើរ ទៅកាន់ថ្នាក់គ្រប់គ្រង(ជាបទពិសោធន៍កន្លងមក បានបង្ហាញថា ជំហ៊ាននេះ គឺមានសារសំខាន់ណាស់ក្នុងការ ផ្សព្វផ្សាយ អំពីការកែប្រែដែលមានលក្ខណៈវិជ្ជមាន)។
- 7. សូមធ្វើការបង្ហាញនូវលទ្ធផល ដែលទទួលបានពីការពិភាក្សាគ្នារបស់ក្រុមការងារ ទៅឲ្យថ្នាក់គ្រប់គ្រង ដើម្បីរៀបចំផែនការអនុវត្តការកែលម្អបន្តទៅមុខទៀត។ [2]

ក្រុមការងារ មិនត្រូវស្ទាក់ស្ទើរក្នុងការស្វែងរកការបំភ្លឺ ពីមន្ត្រីផ្នែកសុវត្ថិភាពនិងសុខភាពការងារ អធិការកិច្ចការងារ អង្គការសុវត្ថិភាពជាតិ ឬសមាគមជាតិជំនាញOSH អង្គការនិយោជក និងអង្គការកម្មករនិយោជិត នោះទេ។

នេះមិនមែនជាបញ្ជី សម្រាប់វិធានការចាំបាច់ទាំងអស់ទេ។ ក្រុមការងារ គួរតែបន្ថែម ចំនុចផ្សេងៗទៀត ទៅក្នុងបញ្ជីត្រួតពិនិត្យដែលពួកគេគិតថាសមស្រប ដើម្បីធ្វើឱ្យប្រសើរឡើង នូវការឆ្លើយតបចំពោះកូវីត-១៩ នៅកន្លែងធ្វើការ។ ថ្នាក់គ្រប់គ្រងចាំបាច់ត្រូវអនុលោម កាតព្វកិច្ចច្បាប់ជាតិ ក្នុងការបង្កើតផែនការ ការពារនិងត្រួតពិនិត្យជំងឺកូវីត-១៩- នៅកន្លែងធ្វើការរបស់ពួកគេ។

[1] អាទិភាពគួរតែត្រូវបានសម្រេចចិត្ត ដោយយោងទៅតាម ភាពអាចនឹងកើតឡើង តិចឬច្រើននៃស្ថានភាពដែលបានផ្តល់ឱ្យប៉ះពាល់ ដល់សុខភាពកម្មករ និងភាពធ្ងន់ធ្ងរ និងបន្ទាន់របស់វា។
[2] ឧបសម្ព័ន្ធ ១

## ▶ I. គោលនយោបាយ ផែនការ និងការរៀបចំចាត់ចែង៖

1) ក្រុមហ៊ុន មានបង្កើត និងបិទផ្សាយនូវសេចក្ដីថ្លែងការណ៍ អំពីឆន្ទៈ និងការទទួលខុសត្រូវ ក្នុងការកាត់បន្ថយនូវការប្រឈម ទៅនឹងហានិភ័យនៃការឆ្លងមេរោគកូវីដ-១៩ នៅកន្លែងការងារ ដោយមានការប្រឹក្សាយោបល់ជាមួយនឹងតំណាងកម្មករនិយោជិត។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

2) បង្កើតនូវផែនការត្រៀម និងឆ្លើយតបពេលមានគ្រោះអាសន្ន ជម្ងឺកូវីដ-១៩នៅកន្លែងការងារ ដោយមានវិសាលភាពគ្របដណ្ដប់ ចំពោះគ្រប់ផ្នែកនៃកន្លែងដែលមានកម្មករនិយោជិតបំពេញការងារ និងកន្លែងដែលប្រឈមទៅនឹង ប្រភពគ្រោះថ្នាក់បង្ករឡើងដោយមេរោគកូវីដ-១៩។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

*យោងតាមគោលការណ៍ណែនាំឆ្នាំ ២០០១ របស់អង្គការ ILO ស្ដីពីប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារ (.10៣.១០.៣ ។) ការរៀបចំសម្រាប់ការការពារ ការឆ្លើយតប និងការត្រៀមលក្ខណៈជាមុនពេលមានអាសន្ន តែត្រូវរៀបចំឡើង ទៅតាមទំហំ និងសកម្មភាពរបស់អង្គការ។ ពួកគេគួរតែត្រូវបានបង្កើតឡើង ដោយសហការជាមួយ អ្នកផ្ដល់សេវាកម្មផ្នែកអាសន្នពីក្រៅ និងអង្គភាពដទៃទៀត ដែលអាចអនុវត្តបាន ហើយនឹងធានាថាព័ត៌មានសំខាន់ៗ ការប្រាស្រ័យទាក់ទងផ្ទៃក្នុង និងការសម្របសម្រួល ត្រូវបានផ្ដល់ដើម្បីការពារប្រជាជនទាំងអស់ ក្នុងករណី មានភាពអាសន្ននៅកន្លែងធ្វើការ; ផ្ដល់ព័ត៌មាន និងការទំនាក់ទំនង ជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ និងអ្នកនៅជិតៗនោះ រួមទាំងសេវាកម្មឆ្លើយតបបន្ទាន់; ផ្ដល់ជំនួយសង្គ្រោះបឋម និងជំនួយផ្នែកវេជ្ជសាស្ត្រ ការពន្លត់អគ្គីភ័យ និងការជម្លៀសប្រជាជនទាំងអស់ ពីនៅកន្លែងធ្វើការ និងផ្ដល់ព័ត៌មាន និងការបណ្ដុះបណ្ដាលដល់សមាជិក ដែលពាក់ព័ន្ធទាំងអស់ រួមទាំងការធ្វើលំហាត់សមត្រៀមបង្ការ និងនីតិវិធីឆ្លើយតបបន្ទាន់ ជាទៀងទាត់។*

3) ធ្វើការប្រឹក្សាយោបល់ ឲ្យបានទៀងទាត់ជាមួយ នឹងអ្នកផ្ដល់សេវាកម្មផ្នែកសុខភាព និងសុវត្ថិភាព អាជ្ញាធរទទួលបន្ទុក ផ្នែកសុខភាពសាធារណៈ ឬដៃគូផ្សេងទៀត ដែលបានបង្កើតនូវឯកសារផ្សព្វផ្សាយអប់រំក្នុងការបង្ការ និងកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគ នៅកន្លែងការងារ និងការណែនាំផ្នែកបច្ចេកទេស ផ្សេងទៀត។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

4) បង្កើតឲ្យមានប្រព័ន្ធការងារច្បាស់លាស់ ក្នុងការផ្ដល់នូវពត៌មានថ្មីៗស្ដីអំពីស្ថានភាពនៃមេរោគកូវីដ-១៩ ដោយមានអំណះអំណាងច្បាស់លាស់ពីអាជ្ញាធរជាតិ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

5) ធ្វើការកំណត់នូវប្រភពគ្រោះថ្នាក់ ចេញពីការប្រតិបត្តិការងារទាំងអស់នៅក្នុងក្រុមហ៊ុន។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

6) ធ្វើការរួមបញ្ចូលនូវសុវត្ថិភាព និងសុខភាព ទៅក្នុងផែនការត្រៀមពេលមានអាសន្ន និងផែនការសម្រាប់ ដំណើរការអាជីវកម្ម ពេលមានគ្រោះអាសន្ន និងផែនការផ្សេងទៀត ទាក់ទងទៅនឹងកម្លាំងពលកម្មដែលត្រូវការចាំបាច់ រួមទាំងទីកន្លែងដែលត្រូវការ សម្រាប់ដំណើរការអាជីវកម្ម ឬសង្វាក់ផលិតកម្មជាមួយនឹងកម្លាំង ពលកម្មជាអប្បបរមា។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

7) ផ្សព្វផ្សាយអំពីការងារពីចម្ងាយ(អនឡាញ) សម្រាប់កម្មករនិយោជិតដែលមិនចាំបាច់ត្រូវធ្វើការ នៅក្នុងកន្លែងការងារ ដើម្បីកាត់បន្ថយការរីករាលដាលនៃមេរោគកូវីដ-១៩ នៅកន្លែងការងារ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ  បាទ/ចាំ  អាទិភាព

កំណត់សម្គាល់:

8) ប្រសិនបើធ្វើការពីចម្ងាយ មិនអាចធ្វើទៅបាន សូមណែនាំអំពីការរៀបចំវេនធ្វើការ ដើម្បីកាត់បន្ថយការប្រមូលផ្តុំកម្មករនិយោជិតទ្រង់ទ្រាយធំ នៅក្នុងអគារការងារ ឬអគារផលិតកម្ម។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

9) បង្កើតផែនការសកម្មភាព សម្រាប់អនុវត្ត ប្រសិនបើមានករណីសង្ស័យឆ្លងជម្ងឺកូវីដ-១៩ ត្រូវបានរកឃើញ នៅក្នុងកន្លែងការងាររួមទាំងនិតិវិធីក្នុងការរាយការណ៍ តាមដាន ត្រួតពិនិត្យ និងការសម្អាតមេរោគនៅក្នុងកន្លែងការងារ ទៅតាមសេចក្តីណែនាំរបស់អាជ្ញាធរជាតិ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

10) អនុលោមទៅតាមច្បាប់ជាតិ ចំពោះការអនុញ្ញាតច្បាប់ឈឺដោយមានប្រាក់ឈ្នួល អត្ថប្រយោជន៍ពេលឈឺ និង ច្បាប់ថែទាំផ្សេងៗ ដោយធ្វើការជូនដំណឹង ឲ្យកម្មករនិយោជិតបានដឹងផងដែរ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

11) បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃទៅលើផែនការ រួមទាំងយុទ្ធសាស្រ្តបង្ការការឆ្លងជម្ងឺកូវីដ-១៩។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

## ▶ II. ការកំណត់ និងវាយតម្លៃហានិភ័យ ការគ្រប់គ្រង និងការប្រាស្រ័យទាក់ទង៖

12) កំណត់សក្តានុពល នៃហានិភ័យទៅលើ ការធ្វើទំនាក់ទំនងគ្នារវាងកម្មករនិយោជិត អ្នកម៉ៅការ អតិថិជន និងភ្ញៀវនៅក្នុងកន្លែងការងារ និងយន្តការរាំងខ្ទប់ និងរក្សាទុកករណីសង្ស័យនិងអនុវត្តនូវវិធានការនានា។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

13) ធ្វើការបណ្តុះបណ្តាលដល់អ្នកគ្រប់គ្រង កម្មករនិយោជិត និងតំណាងកម្មករអំពីវិធានការបង្ការ ទៅលើហានិភ័យនៃការប្រឈមទៅនឹងជម្ងឺកូវីដ-១៩ និងរបៀបឆ្លើយតបពេលមានការឆ្លងជម្ងឺកូវីដ-១៩។ សម្រាប់កម្មករនិយោជិត ដែលមានហានិភ័យខ្ពស់ត្រូវធ្វើការបណ្តុះបណ្តាលពួកគាត់ អំពីការប្រើប្រាស់ ថែទាំ និង បោះចោលនូវឧបករណ៍ការពារខ្លួនឲ្យបានត្រឹមត្រូវ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

14) ជូនដំណឹងដល់កម្មករនិយោជិត អំពីសិទ្ធិក្នុងការដកខ្លួនចេញពីស្ថានភាពការងារ ដែលប្រថុយទៅនឹងគ្រោះថ្នាក់ដល់ជីវិត ឬធ្ងន់ធ្ងរដល់ជីវិតឬសុខភាព ដោយអនុលោមទៅតាមច្បាប់ជាតិ និងដាក់ចេញនូវនិតិវិធីផ្សេងៗ បូករួមទាំងការជូនដំណឹង ទៅកាន់ប្រធានរបស់ខ្លួនជាបន្ទាន់ស្តីអំពីស្ថានភាពនោះ។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

15) ជួយដល់កម្មករនិយោជិតផ្នែកដឹកជញ្ជូន អ្នកបើកបរ និងកម្មករដែលធ្វើដំណើរក្នុងការកាត់បន្ថយនូវ ការប៉ះពាល់ផ្ទាល់ជាមួយនឹងអតិថិជននិងធានាថា ការអនុវត្តអនាម័យផ្ទាល់ខ្លួនដូចជា លាងដៃនិងការប្រើប្រាស់ ឧបករណ៍ ឬសម្ភារៈសម្រាប់អនាម័យ។ គួរពិចារណាក្នុងការផ្តល់នូវឧបករណ៍ការពារខ្លួន ប្រសិនបើកម្មករ និយោជិតមានប្រស្រ័យទាក់ទងផ្ទាល់ជាមួយនឹងអតិថិជន។

តើអ្នកត្រូវការសំណូមពរ ឲ្យមានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

16) ការធ្វើដំណើរគួរតែចៀសវាង ប្រសិនបើមិនចាំបាច់។ ត្រូវធ្វើការកំនត់នូវហានិភ័យនៃការឆ្លងជម្ងឺ កូវីដ-១៩ នៅពេលធ្វើដំណើរសម្រាប់អាជីវកម្ម ទៅតាមផែនការដែលបានកំណត់។ [3]

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

17) រក្សានូវការប្រាស្រ័យទាក់ទង ឲ្យបានទៀងទាត់ ជាមួយនឹងកម្មករនិយោជិត និងតំណាងកម្មករ តាមរយៈមធ្យោបាយផ្សេងៗ រួមទាំង ការប្រើប្រាស់តាមបណ្ដាញអ៊ីនធើណែត ឬទូរស័ព្ទ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

18) ជួយកម្មករនិយោជិត ក្នុងការគ្រប់គ្រងទៅលើហានិភ័យ ផ្លូវចិត្តក្នុងពេលមានគ្រោះអាសន្ន តាមរយៈការណែនាំ និងផ្សព្វផ្សាយអំពីទម្រង់ថ្មី នៃការរៀបចំការងារ ការថែទាំសុខភាព ការរស់នៅ រួមទាំងការហូបចុក ការសម្រាក គេង ការហាត់ប្រាណ និងការប្រាស្រ័យទាក់ទងជាមួយនឹងមិត្តភក្តិ និងគ្រួសារ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

## ▶ III.វិធានការបង្ការ និងកាត់បន្ថយ៖

19) រៀបចំការងារក្នុងមធ្យោបាយ ដែលអាចរក្សាគម្លាតអោយបានយ៉ាងហោចណាស់ ២ ម៉ែត្រ (៦ ហ្វីត) ពីគ្នា ឬចម្ងាយណាមួយដែលមានការណែនាំពីអាជ្ញាធរមានសមត្ថកិច្ច និងពាក់ព័ន្ធ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

20) ចៀសវាងការប្រជុំទល់មុខគ្នា បើអាចគឺប្រជុំតាមទូរស័ព្ទ អ៊ីម៉ែល ឬអនឡាញផ្សេងៗ។ ប្រសិនបើអ្នកចាំបាច់ ក្នុងការប្រជុំទល់មុខគ្នា ត្រូវរៀបចំអោយមានគម្លាតពីគ្នា តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

21) ផ្ដល់នូវកន្លែងលាងដៃ ដែលងាយស្រួល ដូចជាសាប៊ូ និងទឹកគ្រប់គ្រាន់ ដល់កម្មករនិយោជិត អតិថិជន និងភ្ញៀវ សម្រាប់អនាម័យដៃ ហើយការអនុវត្តទាំងនេះ ក៏បានចូលរួម ក្នុងការបង្កើតវប្បធម៌លាងដៃផងដែរ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

22) ដាក់នូវឧបករណ៍ ឬសម្ភារៈអនាម័យ នៅកន្លែងដែលងាយស្រួលមើលឃើញ និងប្រើប្រាស់ក្នុងកន្លែងការងារ ហើយត្រូវធានានៅក្នុងឧបករណ៍នេះ មានសារធាតុលាង ឬជូតដៃគ្រប់គ្រាន់ និងបំពេញបន្ថែមជាប្រចាំ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

23) លើកកម្ពស់វប្បធម៌ ជូតសម្អាតកន្លែងការងារដូចជា តុ កៅអី ឬមណ្ឌលការងារ ដៃបិទបើកទ្វារ ទូរស័ព្ទក្ដារចុចកុំព្យូទ័រ និងរបស់របរផ្សេងៗ នៅកន្លែងការងារ ដោយប្រើប្រាស់សារធាតុសម្លាប់ ឬសម្អាតមេរោគ និងកន្លែងផ្សេងទៀត ដែលប្រើប្រាស់រៀងរាល់ថ្ងៃគឺបន្ទប់ទឹក។ សម្អាតផ្ទៃ នៃទីកន្លែង ដែលប៉ះពាល់ញឹកញាប់។ អាចពិចារណាទៅលើសេវាកម្មសម្អាត ឬសម្លាប់មេរោគ អាស្រ័យទៅលើការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ បាទ/ចាំ អាទិភាព

កំណត់សម្គាល់:

[3] សម្រាប់ព័ត៌មានបន្ថែម៖ https://www.who.int/emergencies/diseases/novel-coronavirus-2019/travel-advice

24) កែលម្អឲ្យប្រសើរឡើង នូវប្រព័ន្ធខ្យល់ចេញចូល និងសម្អាតបន្ទប់ ឬកន្លែងការងារ ដែលអាចមានហានិភ័យខ្ពស់ ក្នុងការប្រឈមទៅនឹងការឆ្លងមេរោគ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

25) លើកកម្ពស់ និងផ្សព្វផ្សាយ អំពីការរក្សាអនាម័យផ្លូវដង្ហើមនៅកន្លែងការងារដូចជា ការខ្ទប់ឬបិទមាត់ ច្រមុះដោយប្រើប្រាស់កែងដៃ ឬក្រដាសជូតមាត់ នៅពេលដែលក្អក ឬកណ្តាស់។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

26) ធានាថា គម្លាតសង្គមនៅកន្លែងការងារ ត្រូវបានអនុវត្តដើម្បីជៀសវាងការប្រមូលផ្តុំ ដែលអាចធ្វើបាន។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

27) ផ្តល់នូវម៉ាស់ការពារ និងក្រដាសជូតមាត់ នៅក្នុងកន្លែងការងារឲ្យបានគ្រប់គ្រាន់សម្រាប់អ្នកដែល ហូរសំបោរ ក្អក ឬ កណ្តាស់ ដោយមានធុងសម្រាម ដាក់នៅជិតសម្រាប់ប្រើប្រាស់ នៅពេលដែលបោះចោលនូវ សម្ភារៈដែលប្រើប្រាស់រួច ក្នុងគោលបំណងរក្សាអនាម័យនៅក្នុងកន្លែងការងារ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

## ▶ IV. ការរៀបចំជាមុន សម្រាប់ករណីសង្ស័យឆ្លងមេរោគកូវីដ-១៩

28) លើកទឹកចិត្តដល់កម្មករនិយោជិត មិនបាច់មកធ្វើការក្នុងករណីសង្ស័យថា មានអាការៈនៃការឆ្លងជម្ងឺកូវីដ-១៩ ដោយអនុលោមទៅតាម សេចក្តីណែនាំរបស់អាជ្ញាធរដែលបានជូនដំណឹង។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

29) ណែនាំកម្មករនិយោជិត ឲ្យធ្វើការទំនាក់ទំនង ទៅកាន់អ្នកផ្តល់សេវាសុខភាព ឬមន្ទីរពេទ្យរដ្ឋ នៅពេលដែលពួកគេមានបញ្ហាសុខភាពធ្ងន់ធ្ងរដូចជា ពិបាកដកដង្ហើម ដោយតម្រូវឲ្យផ្តល់ព័ត៌មានលម្អិត ស្តីអំពីប្រវត្តិនៃការធ្វើដំណើរផង និងអាការៈផងដែរ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

30) រៀបចំអោយមានកន្លែងដាច់ដោយឡែក សម្រាប់បុគ្គលដែលមានអាការៈនៃជម្ងឺកូវីដ-១៩ នៅកន្លែងការងារ ឬនៅពេលដែលរង់ចាំការមកទទួលទៅកាន់មន្ទីរពេទ្យ។ រៀបចំសម្អាត នៅកន្លែងការងារដែលមានអ្នកឆ្លង ឬសង្ស័យដើម្បីសម្លាប់មេរោគ និងតាមឃ្លាំមើលអ្នកដែលស្និទ្ធស្នាលផងដែរ។

តើអ្នកត្រូវការសំណូមពរឲ្យ មានសកម្មភាពដែរឬទេ?

ទេ    បាទ/ចាំ    អាទិភាព

កំណត់សម្គាល់:

[4] ដាក់នៅកន្លែង ដែលមានមនុស្សជួបជុំ និងប្រមូលផ្តុំ ដូចជាហាងកាហ្វេជាដើម។

# ឧបសម្ព័ន្ធ ទី១

## ទម្រង់ផែនការសកម្មភាព និងការតាមដាន

### 1. ផែនការសកម្មភាព

អគារ/ផ្នែក៖_______________________________________________________________

កាលបរិច្ឆេទ៖ ________________

ក្រុម៖ ________________

ផ្នែកបច្ចេកទេស៖

[ ] គោលនយោបាយ ផែនការ និង ការរៀបចំចាត់ចែង

[ ] ការកំនត់និងវាយតម្លៃហានិភ័យ ការគ្រប់គ្រង និងការប្រាស្រ័យទាក់ទង

[ ] វិធានការបង្ការ និងការកាត់បន្ថយ

[ ] ការរៀបចំទុកជាមុន សម្រាប់ករណីសង្ស័យឆ្លងមេរោគកូវីដ-១៩

[ ] ផ្សេងៗ ________________

____________________________________________________________

ការបរិយាយ អំពីការរំពឹងទុកក្នុងការកែលម្អ៖
______________________________________________________________

______________________________________________________________

______________________________________________________________

ទីកន្លែង៖______________________________________________________________

ការបរិយាយ៖______________________________________________________________

______________________________________________________________

______________________________________________________________

ការប៉ាន់ប្រមាណថ្ងៃបញ្ចប់៖

______________________________________________________________

______________________________________________________________

• សន្លឹកដាច់ដោយឡែក គួរតែត្រូវបានប្រើ សម្រាប់ការកែលម្អផ្នែកបច្ចេកទេសផ្សេងៗគ្នា។

## 2. សកម្មភាពតាមដាន(ស្តីអំពីព័ត៌មាន នៃសកម្មភាព ដែលបានធ្វើឬកែលម្អ)

កាលបរិច្ឆេទ៖ ________________________________________________

ក្រុម៖ ________________________________________________

អគារ/ផ្នែក៖ ________________________________________________

ចំណុចដែលបានកែលម្អ ឬ កំពុងកែលម្អ៖

____________________________________________________________________________

____________________________________________________________________________

____________________________________________________________________________

ផ្នែកបច្ចេកទេស៖

[ ] គោលនយោបាយ ផែនការ និងការរៀបចំចាត់ចែង

[ ] ការកំនត់និងវាយតម្លៃហានិភ័យ ការគ្រប់គ្រង និងការប្រាស្រ័យទាក់ទង

[ ] វិធានការបង្ការ និងការកាត់បន្ថយ

[ ] ការរៀបចំទុកជាមុន សម្រាប់ករណីសង្ស័យឆ្លងមេរោគកូវីដ-១៩

[ ] ផ្សេងៗ ____________________

កាលបរិច្ឆេទនៃការកែលម្អ៖ _________________________________________________________________

ឈ្មោះអ្នកដែលទទួលខុសត្រូវ៖ ____________________________________________________________

រយៈពេលចាំបាច់ សម្រាប់បញ្ចប់ការកែលម្អ៖ _______________________________________________

ជំនាញ និងបច្ចេកទេសដែលចាំបាច់ដើម្បីកែលម្អ៖ ____________________________________________________________________

ចំណុចដែលអាចកែលម្អបាន៖

____________________________________________________________________________

____________________________________________________________________________

____________________________________________________________________________

ចំណុចខ្លាំង សម្រាប់ធ្វើការកែលម្អ៖ ____________________________________________________________________________

____________________________________________________________________________

____________________________________________________________________________

ការគាំទ្រចាំបាច់ សម្រាប់ការអនុវត្តកែលម្អ (រួមទាំងការជួយគាំទ្រ ពីអាជ្ញាធរ ផ្នែកសុខភាព និងសុវត្ថិភាព)៖